

*សេចក្ដីផ្ដើម*

# ចូរយើងអធិស្ឋាន

## ការនិយាយទៅកាន់ព្រះ តាមលំនាំក្នុងព្រះគម្ពីរបរិសុទ្ធ

ព្រះគម្ពីរបានកត់ទុកនូវសេចក្ដីអធិស្ឋានជាច្រើន ដែលជាអំណោយដ៏អស្ចារ្យ ដែលព្រះប្រទាន ហើយមានការបង្រៀនជាច្រើន សម្រាប់យើងរាល់គ្នា។ ការអធិស្ឋានទាំងនោះជួយឲ្យយើងយល់ពីរបៀបអធិស្ឋាន តាមគំរូរបស់ព្រះយេស៊ូវ លោកយ៉ូប លោកម៉ូសេ ស្ដេចដាវីឌ លោកសាំយ៉ូអែល លោកអេសាយ លោកយេរេមា នាងម៉ារា លោកពេត្រុស សាវ័កប៉ុល និងមនុស្សជាច្រើនទៀត។ គំរូនៃការអធិស្ឋានទាំងនោះ ក៏អាចជួយឲ្យយើងនិយាយទៅកាន់ព្រះផងដែរ។ ពេលដែលព្រះយេស៊ូវហៀបនឹងសុគត ព្រះអង្គបានអធិស្ឋាន តាមលំនាំស្ដេចដាវីឌ(ម៉ាថាយ ២៧:៤៦ ទំនុកដំកើង ២២:១ និងលូកា ២៣:៤៦ ទំនុកដំកើង ៣១:៥) ដូចនេះ យើងក៏អាចយកគំរូតាមព្រះអង្គ ដោយស្វែងរកពាក្យពេចន៍ ក្នុងលំនាំនៃសេចក្ដីអធិស្ឋាន ដែលមានចែងក្នុងព្រះគម្ពីរ ដែលអាចជួយពាំនាំចិត្តគំនិត និងអារម្មណ៍របស់យើង ទៅរកព្រះអង្គ។ កាលណាយើងប្រើអធិស្ឋាន តាមលំនាំដែលមានក្នុងព្រះបន្ទូលព្រះ ដោយការបន្ទាបខ្លួន និងការរំពឹងគិត ដើម្បីលើកទឹកចិត្តខ្លួនឯង ក្នុង

ការអធិស្ឋានរបស់យើង គឺមានន័យថា យើងកំពុងបើកចិត្ត និងជីវិតយើង ឲ្យមានជំនឿកាន់តែរឹងមាំ ឲ្យបានទទួលកម្លាំង និងព្រះពរជាថ្មី ហើយឲ្យបានទទួលអំណាចបេស្កាពីព្រះអង្គ។

ព្រះទ្រង់បានអញ្ជើញយើង ឲ្យចូលទៅជិតព្រះអង្គ កាន់តែស្និទ្ធស្នាល តាមរយៈសេចក្តីអធិស្ឋាន ដែលមានចែងក្នុងព្រះគម្ពីរ។ ព្រះវិញ្ញាណព្រះអង្គ "ជួយយើងពេលយើងមានភាពកម្សោយ"(រ៉ូម ៨:២៦)។ ពេលដែលយើងអធិស្ឋានតាមលំនាំដែលមានក្នុងព្រះគម្ពីរ ព្រះវិញ្ញាណបរិសុទ្ធក៏ជួយឲ្យការអធិស្ឋានរបស់យើង មានជីវិតឡើង។

James Banks

## *អគ្គការនំម៉ាណាប្រចាំថ្ងៃ*

# មាតិកា

ទី១

ការអធិស្ឋាន ដើម្បីសរសើរដំកើង និងគោរពព្រះ..................5

ទីពីរ

ការអធិស្ឋានដើម្បីលន់តួបាប និងបន្ទាបខ្លួន........................11

ទី៣

ការអធិស្ឋានសម្រាប់តម្រូវការប្រចាំថ្ងៃ................................17

ទី៤

អធិស្ឋានសូមការដឹកនាំ និងទិសដៅ................................23

ទី៥

អធិស្ឋាន ដើម្បីពោលពាក្យអរព្រះគុណ............................27

អ្នកគ្រប់គ្រងផ្នែកកែសម្រួលអត្ថបទ : J. R. Hudberg
រចនាក្របដោយ: Stan Myers
រូបភាពក្របដោយ: Brian A. Jackson / Thinkstock
រចនាផ្នែកខាងក្នុងដោយ: Steve Gier
ប្រែសម្រួលជាភាសាខ្មែរ ដោយ : លោក ឯក សត្យា
បទគម្ពីរជាភាសាខ្មែរដកស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធ ភាសាខ្មែរ បកប្រែចាស់ ឆ្នាំ១៩៥៤
ដោយការអនុញ្ញាតិ និងរក្សាសិទ្ធិដោយសមាគមន៍ព្រះគម្ពីរសេកល។
រក្សាសិទ្ធិគ្រប់យ៉ាងដោយ: © 2015 ODB Ministries ( website: www.odb.org )
ចេញផ្សាយដោយ : ODB Cambodia ( email: cambodia@rbc.org, Tell: 087 233 907, website: http://khmer-odb.org, FB page : https://www.facebook.com/RBCCambodia )



*ទី១*

# ការអធិស្ឋាន ដើម្បីសរសើរដំកើង និងគោរពព្រះ

មានកន្លែងដ៏ល្បីឈ្មោះមួយ នៅមិនឆ្ងាយពីផ្ទះខ្ញុំ។ គេហៅកន្លែងនោះថា រូងសេននេត។ បើអ្នកដើរពីផ្ទះរបស់ខ្ញុំ កាត់តាមព្រៃ ចម្ងាយប្រហែលកន្លះគីឡូម៉ែត្រ នោះអ្នកនឹងបានទៅដល់កន្លែងដ៏គួរឲ្យចាប់អារម្មណ៍ នៅត្រង់ចំណុចរបត់នៃស្ទឹងអេណូ ដែលមានផ្ទាំងថ្មក្រានីត និងដើមឈើចាស់ៗជាច្រើនព័ទ្ធជុំវិញ។ អ្នកស្រុកបាននិយាយថា កាលពីទសវត្សរ៍ឆ្នាំ១៧០០ មានអ្នកត្រួសត្រាយផ្លូវម្នាក់បានសាងសង់រោងកិនស្រូវ នៅកន្លែងនោះ ហើយគាត់ក៏បានបាត់បង់ជីវិតនៅក្នុងជម្រៅទឹកស្ទឹងនោះ ពេលដែលទឹកជំនន់នៅរដូវផ្ការីក បានធ្វើឲ្យទឹកស្ទឹងនោះហូរយ៉ាងគំហុក។ មានមនុស្សមិនតិចទេ ដែលត្រូវចរន្តទឹកដ៏លឿនឆក់យកទៅ នៅត្រង់ចំណុចរបត់របស់ស្ទឹងនោះ បានជាមានក្រុមស្វែងរកនិងជួយសង្គ្រោះ មកទីកន្លែងនោះជាញឹកញាប់។

ប៉ុន្តែ ស្ទឹងនោះច្រើនតែមានចរន្តទឹកខ្សោយ ដែលទាក់ទាញមនុស្សជាច្រើនមកឲ្យកម្សាន្តនៅទីនោះ។ នៅពេលរសៀលថ្ងៃមួយ ក្នុងរដូវក្តៅ ខ្ញុំនិងកូនប្រុសរបស់ខ្ញុំ ដែលមានអាយុ១៣ឆ្នាំ បាននាំគ្នាដើរកម្សាន្ត តាមមាត់ទឹកដ៏ត្រជាក់នៅកន្លែងនោះ ពេលអាកាសធាតុក្តៅហែង ដោយមានសត្វឆ្កែប្រម៉ាញ់របស់យើងឈ្មោះ"ប៊ែរ"(ប្រែមកថា សត្វខ្លាឃ្មុំ) ដើរត្រេកៗនៅក្បែរយើង ដោយក្តីរីករាយ។

នៅត្រើយម្ខាងស្ទឹង មានខ្សែពួរមួយ ដែលគេបានចងទន្លាក់ពីលើមែកដើមឈើដ៏រឹងមាំមួយដើម ដែលគេអាចតោងយោងខ្លួន លោតចូលទឹកលេងកម្សាន្តបាន។

ពេលដែលសត្វឆ្កែនិងកូនប្រុសខ្ញុំវាកំពុងលោតពីផ្ទាំងថ្ម មួយទៅផ្ទាំងថ្មមួយទៀត នៅតាមមាត់ទឹក ខ្ញុំក៏បានហែលទឹកទៅរកខ្សែពួរនោះ ហើយក៏បានស្រែកហៅពួកគេ ដើម្បីឲ្យដឹងថា ខ្ញុំបានទៅដល់កន្លែងហ្នឹងហើយ។

គ្រាន់តែសត្វឆ្កែខ្ញុំបានឮសម្លេងខ្ញុំភ្លាម វាក៏បានលោតចូលទៅក្នុងទឹកស្ទឹង ហើយក៏ចាប់ផ្តើមហែលខ្ទៃៗមករកខ្ញុំ ដែលនៅចម្ងាយប្រហែល១០០ម៉ែត្រ។ ខ្ញុំក៏បានតោងខ្សែពួរនោះ យោលខ្លួនទម្លាក់ចូលទៅក្នុងទឹក ហើយហែលទៅរកវា។ យើងក៏បានហែលទៅរកត្រើយម្ខាងទាំងអស់គ្នា។

សកម្មភាពកាលពីពេលរសៀលថ្ងៃនោះ បានបង្រៀនខ្ញុំអំពីសេចក្តីស្រឡាញ់។ ពេលដែលសត្វឆ្កែខ្ញុំបានឮសម្លេងខ្ញុំភ្លាម វាហ៊ានលោតចូលក្នុងទឹក ហើយហែលទៅរកខ្ញុំភ្លាម ដោយមិនខ្លាចគ្រោះថ្នាក់។ វាបានធ្វើឲ្យខ្ញុំស្រឡាញ់វាកាន់តែខ្លាំង ហើយក៏បានធ្វើឲ្យខ្ញុំមានចម្ងល់ផងដែរ។ ខ្ញុំ ស្រឡាញ់សត្វឆ្កែរបស់ខ្ញុំ ដោយសារវាមានចិត្តក្លាហាន ដោយសេចក្តីស្រឡាញ់ចំពោះខ្ញុំ ចុះចំណែកឯព្រះវរបិតាដែលល្អឥតខ្ចោះ ដែលគង់នៅស្ថានសួគ៌វិញ(ដែលបានបង្កើតយើង ឲ្យមានរូបភាពដូចព្រះអង្គ) តើព្រះអង្គនឹងមានការឆ្លើយតបយ៉ាងណាចំពោះយើង ពេលដែលយើងហ៊ាន អរសប្បាយចំពោះព្រះអង្គ?

***សេចក្តីស្រឡាញ់ជម្រុញឲ្យមានសកម្មភាព។*** *ការនេះបានឆ្លុះបញ្ចាំងអំពីការអ្វីដែលព្រះបានធ្វើសម្រាប់យើង ក្នុងការយាងចុះមកយកកំណើតជាមនុស្ស ព្រោះតែសេចក្តីស្រឡាញ់ និងដើម្បីជួយឲ្យយើងផ្សះផ្សាទំនាក់ទំនងជាមួយព្រះឡើងវិញ ក្នុងអង្គព្រះយេស៊ូវ។ បទគម្ពីរ ទំនុកដំកើង ៣៧:៤ បានប្រាប់យើងថា ពេលដែលយើងអរសប្បាយក្នុងព្រះអម្ចាស់ ព្រះអង្គក៏បណ្តាលចិត្តយើង ឲ្យមានបំណងចិត្ត ដែលឆ្លុះបញ្ចាំងបំណងព្រះទ័យព្រះអង្គ។*

ការសរសើរដំកើងដ៏ពិត ជាការសរសើរដំកើង ដោយសេចក្តីជំនឿដ៏សកម្ម ដែលប្រសើរជាងការសរសើរដំកើង ដែលប្រើតែអារម្មណ៍។ ការសរសើរដំកើងដ៏ពិត គឺបានធ្វើឡើងដោយចិត្តក្លាហាន។ ការសរសើរដំកើងដ៏ពិតចាក់ចុចចិត្តយើង ឲ្យលះចោលផ្លូវចាស់នៃចិត្តរបស់យើង ហើយឈោងទៅរកការអ្វីដែលធំលើសយើង ដោយថ្វាយខ្លួនយើងដាច់ដល់ព្រះ។ ការសរសើរដំកើងមិនកើតមានចំពោះខ្ញុំ ដោយ

ឯកឯងឡើយ។ ខ្ញុំមានការតយុទ្ធចំពោះខ្លួនឯង ដែលជាចរន្តទឹកដ៏គ្រោះថ្នាក់ ដែលហូរយ៉ាងគំហុក ក្នុងជម្រៅចិត្តខ្ញុំ។ ជាការពិតណាស់ ព្រះគម្ពីរប្រាប់ខ្ញុំឲ្យ "អរសប្បាយជានិច្ច" "មិនត្រូវឈប់អធិស្ឋាន" ហើយព្រះអង្គសព្វព្រះទ័យឲ្យខ្ញុំ "អរព្រះគុណព្រះអង្គ គ្រប់កាលៈទេសៈ"(១ថែស្សាឡូនិច ៥:១៦-១៨) តែក៏មានពេលដែលខ្ញុំមិនមានអារម្មណ៍ថា ចង់អរសប្បាយ ឬចង់អធិស្ឋាន ឬមួយចង់អរព្រះគុណព្រះអង្គឡើយ។ តែដោយសារព្រះគុណព្រះ នោះខ្ញុំក៏បានដឹងបន្តិចម្តងៗថា ការអសប្បាយមិនគ្រាន់តែជាអារម្មណ៍របស់យើងទេ តែក៏ជាការអ្វីដែលយើងធ្វើផងដែរ។



*"ការសរសើរដំកើងដ៏ពិតចាក់ចុចចិត្តយើង ឲ្យលះចោលផ្លូវចាស់នៃចិត្តរបស់យើង ហើយឈោងទៅរកការអ្វីដែលធំលើសយើង ដោយថ្វាយខ្លួនយើងដាច់ដល់ព្រះអង្គ"។*

ព្រះអង្គបានបញ្ជាយើងឲ្យ "អរសប្បាយ" ក្នុងព្រះអង្គ។ ត្រង់ចំណុចនេះ បទគម្ពីរទំនុកដំកើង ៣៧:៤ ជាព្រះរាជបញ្ជាដែលបង្គាប់ឲ្យយើងអរសប្បាយ។ ពេលដែលយើងមានអារម្មណ៍ពេញចិត្តនឹងស្ថានភាពរបស់ខ្លួនឯងហើយមិនចង់ពឹងផ្អែកលើព្រះអង្គ ព្រះរាជបញ្ជានេះបានចាក់ចុចចិត្តយើង ហើយត្រាស់ហៅយើង ឲ្យមានគំនិតដែលខ្ពស់ជាងនេះ។ នោះមិនមែនជាការងាយទេ ព្រោះយើងត្រូវមានការលះបង់អ្វីម្យ៉ាង។

ព្រះទ្រង់មិនដែលទុកយើងចោលទេ។ កាលណាយើងខិតខំចូលទៅក្បែរព្រះអង្គ នោះព្រះអង្គបានសន្យាថា ព្រះអង្គក៏នឹងចូលមកចិត្តយើងផងដែរ(យ៉ាកុប ៤:៨)។ ចូរហ៊ានអរសប្បាយក្នុងព្រះ ហើយព្រះអង្គមិនគ្រាន់តែប្រទានឲ្យយើងមានបំណងចិត្ត ដែលត្រូវតាមបំណងព្រះទ័យព្រះអង្គប៉ុណ្ណោះទេ តែព្រះអង្គថែមទាំងបណ្តាលចិត្តយើង ឲ្យប្រាថ្នាចង់បានព្រះអង្គផងដែរ។ ទំព័រជាបន្តបន្ទាប់ទៀតនោះ នឹងនិយាយអំពីការសរសើរដំកើងរបស់រាស្ត្រព្រះអង្គ ដែលព្រះវិញ្ញាណបណ្តាលឡើង។ សូមយកគំរូតាមការសរសើរដំកើងទាំងនោះ ហើយអ្នកនឹងមិនដែលស្តាយក្រោយឡើយ។ ចូរលោតចូល ហើយអធិស្ឋានតាមលំនាំទាំងនេះ ហើយមិនយូរប៉ុន្មាន អ្នកនឹងរកឃើញថា ព្រះទ្រង់កំពុងចូលមកជួបអ្នកមិនខាន។

# លំនាំនៃការអធិស្ឋាន

*គ្មាននរណាខ្លាំងជាងព្រះអង្គឡើយ!*

ឱព្រះយេហូវ៉ាអើយ ព្រះហស្តស្តាំទ្រង់មានឫទ្ធិដ៏វិសេស ឱព្រះយេហូវ៉ាអើយ ព្រះហស្តស្តាំទ្រង់បានបោកពួកខ្មាំងសត្រូវខ្ទេចខ្ទីហើយ គឺទ្រង់បានរំលំពួកអ្នកដែលលើកគ្នាទាស់នឹងទ្រង់ ដោយឫទ្ធានុភាពដ៏ជាធំរបស់ទ្រង់ ទ្រង់បានបញ្ចេញសេចក្ដីក្រោធនៃទ្រង់ សេចក្ដីក្រោធនោះបានបញ្ឆេះគេដូចជាភ្លើងឆេះជញ្ជ្រាំង។-និក្ខមនំ ១៥:៦-៧

*ព្រះអង្គបានបង្កើតអ្វីៗទាំងអស់មក!*

ឱព្រលឹងអញអើយ ចូរសរសើរដល់ព្រះយេហូវ៉ា ឱព្រះយេហូវ៉ា ជាព្រះនៃទូលបង្គំអើយ ទ្រង់ធំក្រៃលែង ទ្រង់ប្រដាប់អង្គដោយយសសក្តិ និងតេជានុភាព ក៏ហ៊ុមអង្គដោយពន្លឺ ដូចជាទ្រង់ព្រះភូសា គឺទ្រង់ដែលលាតផ្ទៃមេឃ ដូចជាលាតបាំង ទ្រង់ដាក់ឫសដំណាក់ទ្រង់នៅក្នុងទឹក ក៏យកពពកធ្វើជារថរបស់ទ្រង់ ហើយទ្រង់យាងលើស្លាបខ្យល់ ទ្រង់យកខ្យល់ធ្វើជាអ្នកជូនដំណឹងរបស់ទ្រង់ ហើយយកអណ្តាតភ្លើងធ្វើជាពួកបំរើទ្រង់ ទ្រង់បានតាំងឫសផែនដី ដើម្បីឲ្យបានមាំ មិនឲ្យត្រូវរញ្ជួយនៅអស់កល្ប ទ្រង់បានគ្របផែនដីដោយទឹកជ្រៅ ដូចជាគ្របដោយអាវ ទឹកនោះក៏គ្របអស់ទាំងភ្នំផង កាលទ្រង់បង្គាប់ នោះទឹកបានហូរទៅ ក៏ប្រញាប់ទៅដោយសូរផ្គររបស់ទ្រង់ អស់ទាំងភ្នំបានដុះឡើង ហើយច្រកទាំងប៉ុន្មានក៏ស្រុតទៅ គឺនៅត្រង់កន្លែងដែលទ្រង់បានកំណត់ឲ្យ ទ្រង់បានដាក់ព្រំខណ្ឌ មិនឲ្យទឹកហូររំលងឡើយ ដើម្បីកុំឲ្យឡើងលិចផែនដីទៀត ទ្រង់ធ្វើឲ្យមានក្បាលទឹកផុះឡើងនៅក្នុងច្រកភ្នំ ទឹកនោះហូរនៅកណ្តាលភ្នំ។ ទ្រង់ស្រោចអស់ទាំងភ្នំពីដំណាក់ទ្រង់ ហើយផែនដីបានពេញដោយផលនៃស្នាដៃទ្រង់ ទ្រង់ធ្វើឲ្យស្មៅដុះឡើងសំរាប់សត្វ ហើយបន្លែសំរាប់មនុស្ស ដើម្បីឲ្យទាំង២បានអាហារពីផែនដីមក ព្រមទាំងស្រាទំពាំងបាយជូរដែលនាំឲ្យចិត្តមនុស្សបានសប្បាយ និងប្រេង សំរាប់ឲ្យមុខគេបានរលើបភ្លឺ ហើយអាហារផង សំរាប់ចំរើនកំឡាំងចិត្តមនុស្ស។ ទ្រង់បានតម្រូវព្រះចន្ទ ទុកសំរាប់ជាទីកំណត់រដូវ ចំណែកព្រះអាទិត្យ ក៏ដឹងពេលដែលត្រូវលិចដែរ ទ្រង់ធ្វើឲ្យងងឹត នោះគឺជាយប់ហើយ ជាពេលដែលគ្រប់ទាំងសត្វនៅព្រៃរមែងចេញមក។ ព្រះយេហូវ៉ាអើយ អស់ទាំងស្នាដៃរបស់ទ្រង់មាន ច្រើនប្រការណាស់ហ្ន៎ ទ្រង់បានធ្វើទាំងអស់ដោយប្រាជ្ញា ផែនដីបានពេញដោយរបស់ដែលទ្រង់បង្កើត។-ទំនុកដំកើង ១០៤:១-

១០,១៣-១៥,១៩-២០,២៤

*គ្មាននរណាអាចវាស់ភាពធំប្រសើររបស់ព្រះអង្គបានឡើយ។*

ឱព្រះដ៏ជាមហាក្សត្រនៃទូលបង្គំអើយ ទូលបង្គំនឹងលើកដំកើងទ្រង់ ហើយនឹងសូមឲ្យព្រះនាមទ្រង់បានពរអស់កល្បជានិច្ច។ ទូលបង្គំនឹងសូមឲ្យទ្រង់បានប្រកបដោយព្រះពររាល់ៗថ្ងៃ ព្រមទាំងសរសើរដល់ព្រះនាមទ្រង់អស់កល្បជានិច្ច។ ព្រះយេហូវ៉ាទ្រង់ធំប្រសើរ គឺគួរសរសើរយ៉ាងក្រៃលែង ឯសណ្ឋានធំប្រសើររបស់ទ្រង់ នោះនឹងរកយល់មិនបាន។ មនុស្សជំណា១នឹងសរសើរស្នាដៃរបស់ទ្រង់ ដល់ជំណា១ទៀត ព្រមទាំងប្រកាសប្រាប់ពីការឥទ្ធិឫទ្ធិរបស់ទ្រង់ផង។ ទូលបង្គំនឹងរំពឹងគិតពីឫទ្ធានុភាពដ៏រុងរឿងឧត្តម ហើយពីការអស្ចារ្យរបស់ទ្រង់ដែរ។ មនុស្សទាំងឡាយនឹងថ្លែងពីឫទ្ធិនៃការដ៏គួរស្ញែងខ្លាចរបស់ទ្រង់ ឯទូលបង្គំ នឹងប្រកាសពីសណ្ឋានដ៏ធំវិសេសនៃទ្រង់ដែរ។ គេនឹងបញ្ចេញសេចក្ដីដែលនឹកចាំពីព្រះហឫទ័យដ៏ល្អប្រសើរ ហើយច្រៀងពីសេចក្ដីសុចរិតរបស់ទ្រង់។-ទំនុកដំកើង ១៤៥:១-៧

*គ្មានការអ្វីដែលពិបាកពេក សម្រាប់ព្រះអង្គឡើយ*



*ព្រះអង្គមិនបានរំពឹងឲ្យយើងដឹកកកាយរកកម្លាំងចិត្ត និងការប្ដេជ្ញាចិត្ត ដែលនៅសេសសល់ក្នុងខ្លួនយើងនេះទេ។ ផ្ទុយទៅវិញ យើងត្រូវទូលសូមឲ្យព្រះអង្គប្រទានកម្លាំងរបស់ព្រះអង្គមកយើងនិយាយរួម គឺយើងសូមឲ្យព្រះអង្គប្រទានឲ្យយើងមានកម្លាំងឡើង។*

ឱព្រះអម្ចាស់យេហូវ៉ាអើយ មើល ទ្រង់បានបង្កើតផ្ទៃមេឃ និងផែនដី ដោយសារព្រះចេស្ដាដ៏ធំរបស់ទ្រង់ និងព្រះពាហុដ៏លើកសំរេច គ្មានអ្វីដែលពិបាកពេកដល់ទ្រង់ទេ។ គឺទ្រង់សំដែងសេចក្ដីសប្បុរស ដល់មនុស្សទាំងពាន់ៗ ហើយក៏សងអំពើទុច្ចរិតរបស់ពួកព្ធយុកោ ទៅលើទ្រូងនៃពួកកូនចៅគេ នៅតាមក្រោយ ទ្រង់ជាព្រះដ៏ធំហើយមានឫទ្ធិ ព្រះនាមទ្រង់ គឺព្រះយេហូវ៉ានៃពួកពលបរិវារ។ ទ្រង់ប្រសប់ក្នុងការជួយគំនិត ហើយក៏មានឫទ្ធិក្នុងការធ្វើ ព្រះនេត្រទ្រង់ទតឃើញអញទាំងផ្លូវរបស់ពួកមនុស្សជាតិ ដើម្បីនឹងសងគ្រប់គ្នាតាមផ្លូវគេប្រព្រឹត្ត ហើយតាមផលនៃកិរិយារបស់គេរៀងខ្លួន។ ទ្រង់ក៏បានធ្វើទីសំគាល់ និងការអស្ចារ្យនៅស្រុកអេស៊ីព្ទ ដរាបដល់សព្វថ្ងៃនេះ ព្រមទាំងនៅពួកអ៊ីស្រាអែល ហើយកណ្ដាលពួកមនុស្សដទៃផង ទ្រង់ក៏បានតាំងកិត្តិនាមរបស់ទ្រង់ឡើងដូចជា

មានសព្វថ្ងៃនេះ។-យេរេមា ៣២:១៧-២០

*ព្រះអង្គបានចាត់ព្រះអង្គសង្គ្រោះដ៏មានអំណាចចេស្តា*

សូមឲ្យព្រះអម្ចាស់ ជាព្រះនៃសាសន៍អ៊ីស្រាអែល បានប្រកបដោយព្រះគុណ ពីព្រោះទ្រង់បានទតមើល ហើយប្រោសលោះរាស្ត្រទ្រង់។ ព្រមទាំងបង្កើតព្រះដ៏មានឥទ្ធិឫទ្ធិ នៅក្នុងពូជហ្លួងដាវីឌ ជាអ្នកបំរើទ្រង់ សំរាប់នឹងជួយសង្គ្រោះយើងផង។ ដូចជាទ្រង់មានព្រះបន្ទូល ដោយមាត់ពួកហោរាបរិសុទ្ធរបស់ទ្រង់ តាំងពីបុរាណមក។ នឹងបើកឲ្យយើងបានសង្គ្រោះ រួចពីកណ្តាប់ដៃពួកខ្មាំងសត្រូវ ដើម្បីឲ្យបានបំរើទ្រង់ ឥតភ័យខ្លាច។ ដោយសេចក្តីបរិសុទ្ធ និងសេចក្តីសុចរិត នៅចំពោះទ្រង់ អស់១ជីវិតយើង។-លូកា ១:៦៨-៧០,៧៤-៧៥

## លោកអ្នកអាចអធិស្ឋាន ដោយផ្តើមដោយពាក្យ តាមលំនាំខាងក្រោម

*តើមាននរណាដែលល្អដូចព្រះអង្គ ?*

ឱព្រះយេហូវ៉ាអើយ តើមានព្រះឯណាឲ្យដូចទ្រង់ តើមានអ្នកឯណាដែលមានសេចក្តីបរិសុទ្ធដ៏វិសេសដូចទ្រង់ ដែលគួរសរសើរដំកើង ហើយក៏ធ្វើការអស្ចារ្យផង?-និក្ខមនំ ១៥:១១

*ព្រះអង្គបានសង្គ្រោះទូលបង្គំ!*

ចូរច្រៀងថ្វាយព្រះយេហូវ៉ា ចូរសរសើរដល់ព្រះយេហូវ៉ាចុះ ដ្បិតទ្រង់បានដោះព្រលឹងរបស់មនុស្សវេទនា ឲ្យរួចចេញពីកណ្តាប់ដៃនៃពួកដែលប្រព្រឹត្តអាក្រក់។-យេរេមា ២០:១៣

*ថ្វាយសិរីល្អទាំងអស់ ដល់ព្រះដ៏មានប្រាជ្ញាតែ១ព្រះអង្គ*

ជាព្រះដ៏មានប្រាជ្ញាតែ១ព្រះអង្គ សូមឲ្យទ្រង់បានសិរីល្អ នៅអស់កល្បរៀងទៅ។-រ៉ូម ១៦:២៧

*ព្រះអង្គសោយរាជ្យ*

ក្រោយនោះមក ខ្ញុំឮសំឡេងយ៉ាងខ្លាំង របស់មនុស្ស១ហ្វូងដ៏ធំ នៅលើស្ថានសួគ៌ថា ហាលេលូយ៉ា សេចក្តីសង្គ្រោះ សិរីល្អ និងព្រះចេស្តា នោះជារបស់ផងព្រះនៃយើងរាល់គ្នាហើយ។ ព្រះអម្ចាស់ដ៏ជាព្រះ ដែលមានព្រះចេស្តាបំផុត ទ្រង់សោយរាជ្យឡើងហើយ។-វិវរណៈ ១៩:១,៦



*ទីពីរ*

# ការអធិស្ឋានដើម្បីលន់តួបាប និងបន្ទាបខ្លួន

ក្នុងចំណោមព្រះនាម និងងាររបស់ព្រះយេស៊ូវ ងារដែលខ្ញុំចូលចិត្តជាងគេ គឺងារមួយដែលពួកផារិស៊ីដាក់ឲ្យព្រះអង្គថា "មិត្តសំឡាញ់របស់មនុស្សមានបាប"។ ខ្ញុំជឿថា ព្រះអង្គក៏សព្វព្រះទ័យនឹងងារនេះជាងគេ។ ព្រះយេស៊ូវមានបន្ទូលថា "កូនមនុស្សបានមក ដើម្បីនឹងរក ហើយជួយសង្គ្រោះដល់មនុស្សបាត់បង់"(លូកា ១៩:១០)។ ការដែលព្រះអង្គមានងារជា "មិត្តសំឡាញ់របស់មនុស្សមានបាប" គឺបានប្រាប់ពីមូលហេតុ ដែលព្រះអង្គបានយាងចុះមក គឺបានប្រាប់ច្បាស់ជាងងារដទៃទៀតរបស់ព្រះអង្គ។ មិត្តសំឡាញ់នឹងនៅតែស្រឡាញ់អ្នក ទោះបីជាអ្នកមិនសមនឹងទទួលសេចក្តីស្រឡាញ់ក៏ដោយ ហើយនឹងចេញទៅរកអ្នក ពេលដែលអ្នកវង្វេងផ្លូវ។ ព្រះយេស៊ូវបានធ្វើការទាំងអស់នេះ ហើយក៏បានធ្វើលើសពីនេះផង គឺដូចដែលមានសេចក្តីថែងថា "គ្មានអ្នកណាមានសេចក្តីស្រឡាញ់ធំជាងនេះ គឺដែលអ្នកណានឹងប្តូរជីវិត ជំនួសពួកសំឡាញ់របស់ខ្លួននោះទេ"(យ៉ូហាន ១៥:១៣)។

ខ្ញុំចូលចិត្តគិតថា ព្រះយេស៊ូវជាមិត្តសំឡាញ់របស់ខ្ញុំ ប៉ុន្តែ មិត្តភាពគឺមានសេចក្តីស្រឡាញ់ទៅវិញទៅមក មិនមែនស្រឡាញ់តែម្ខាងទេ។ ខ្ញុំត្រូវសួរខ្លួនឯងថា "តើខ្ញុំជាមិត្តសំឡាញ់ប្រភេទណា ចំពោះព្រះយេស៊ូវ?" បើសិនជាខ្ញុំបានធ្វើជាមិត្តសំឡាញ់របស់នរណាម្នាក់ នោះខ្ញុំត្រូវយកចិត្តទុកដាក់ចំពោះមិត្តភាពដែលខ្ញុំមានជាមួយគាត់។ ខ្ញុំត្រូវតែមានការប្រុងប្រយ័ត្នចំពោះការអ្វីដែលអាចនាំឲ្យមានការឈឺចាប់ ឬនាំឲ្យយើងឃ្លាតចេញពីគ្នា។ សម្រាប់ព្រះយេស៊ូវវិញ គ្មានការអ្វីដែលធ្វើឲ្យព្រះអង្គឈឺចាប់ ដូចអំពើបាបឡើយ។

ខ្ញុំត្រូវចាំថា អំពើបាបបាននាំឲ្យព្រះអង្គមានការលះបង់ខ្លាំងប៉ុណ្ណា ព្រោះការនឹកចាំនេះ ធ្វើឲ្យខ្ញុំក្លាយជាមិត្តសំឡាញ់កាន់តែល្អ ចំពោះព្រះអង្គ។

*"នោះត្រូវឲ្យយើងចូលទៅជិត(ព្រះ)ទាំងមានចិត្តស្មោះត្រង់ និងចិត្តដឹងពិតប្រាកដ ហើយសេចក្តីជំនឿ ព្រមទាំងមានចិត្តប្រោះព្រំកជាស្អាតរួចពីបញ្ញាចិត្តដែលសៅហ្មងផង ហើយបានលាងរូបកាយនឹងទឹកដ៏ស្អាតដែរ ត្រូវឲ្យយើងរាល់គ្នាកាន់ខ្ជាប់ តាមសេចក្តីបន្ទាល់របស់សេចក្តីសង្ឃឹមនោះ ឥតរវើរវាយ ដ្បិតព្រះដែលបានសន្យានោះ ទ្រង់ស្មោះត្រង់"។-ហេព្រើ ១០:២២-២៣*

ម្យ៉ាងទៀត ការអធិស្ឋានលន់តួបាប និងបន្ទាបខ្លួនតាមលំនាំព្រះគម្ពីរ ក៏បានជួយឲ្យខ្ញុំធ្វើជាមិត្តសំឡាញ់កាន់តែល្អ ចំពោះព្រះអង្គផងដែរ។ លំនាំនៃការអធិស្ឋានទាំងនេះ និយាយអំពីភាពស្មោះត្រង់ គឺដូចដែលមានសេចក្តីចែងថា "ឱព្រះអម្ចាស់យេហូវ៉ាអើយ ទ្រង់ស្គាល់ទូលបង្គំ ជាអ្នកបំរើទ្រង់ហើយ"(២សាំយ៉ូអែល ៧:២០) "តើអ្នកណានឹងស្គាល់អំពើខុសឆ្គងរបស់ខ្លួនបាន សូមជំរះទូលបង្គំឲ្យជ្រះស្អាតពីអំពើលាក់កំបាំងផង"(ទំនុកដំកើង ១៩:១២)។

មានការបន្ទាបខ្លួន ក្នុងលំនាំនៃការអធិស្ឋាននេះ និងមានការរៀបរាប់ចំចំណុចអំពីផលវិបាកនៃអំពើបាប គឺដូចមានសេចក្តីចែងថា "ដ្បិតជីវិតទូលបង្គំនឹងផុតទៅដោយសេចក្តីទុក្ខព្រួយ ហើយអស់ទាំងឆ្នាំនៃអាយុទូលបង្គំ ដោយដំងូរផង កំឡាំងនៃទូលបង្គំចេះតែខ្សោយទៅ ដោយព្រោះសេចក្តីទុច្ចរិតនៃទូលបង្គំ ហើយអស់ទាំងឆ្អឹងទូលបង្គំក៏ខ្សោះទៅដែរ"(ទំនុកដំកើង ៣១:១០)។ "ដ្បិតមានសេចក្តីអាក្រក់ឥតគណនាព័ទ្ធទូលបង្គំជុំវិញ អំពើទុច្ចរិតរបស់ទូលបង្គំ បានតាមទូលបង្គំទាន់ហើយ បានជាទូលបង្គំមិនអាចនឹងងើបឡើងមើលបានឡើយ អំពើទាំងនោះច្រើនជាងសរសៃសក់លើក្បាលទូលបង្គំ ចិត្តទូលបង្គំក៏អស់សង្ឃឹមទៅ"(ទំនុកដំកើង ៤០:១២)។ លំនាំនៃការអធិស្ឋានទាំងនេះបានបង្ហាញច្បាស់នូវភាពបរិសុទ្ធរបស់ព្រះ ហើយបង្ហាញនូវការទទួលស្គាល់ ដោយការបន្ទាបខ្លួនថា ការជំនុំជម្រះអំពើបាប គឺយុត្តិធម៌ ហើយការប្រដៅរបស់អង្គ គឺសមនឹងឲ្យយើងទទួល។

ប៉ុន្តែ យើងក៏នឹងរកឃើញក្តីអំណរផងដែរ។ គឺដូចដែលមានសេចក្តីចែងថា "មានពរហើយ មនុស្សណាដែលការរំលងច្បាប់របស់ខ្លួនបានអត់ទោសឲ្យ គឺដែលបាបរបស់ខ្លួនបានគ្របបាំងហើយ មានពរហើយ មនុស្សណាដែលព្រះយេហូវ៉ាមិន

រាប់ថា ជាអ្នកមានទោស ជាអ្នកដែលគ្មានកលឧបាយនៅក្នុងចិត្តសោះ!"(ទំនុកដំកើង ៣២:១-២)។ ការអធិស្ឋានទាំងនេះ បានបង្ហាញឲ្យយើងស្គាល់ផ្លូវ ឆ្ពោះទៅរកភាពស្លូតត្រង់ និងក្តីអំណរដែលព្រះទ្រង់សព្វព្រះទ័យនឹងប្រទានឲ្យ។

អ្នកនិពន្ធទំនុកដំកើងបានរំឭកយើងថា "បើសិនជាខ្ញុំឃើញមានសេចក្តីទុច្ចរិតនៅក្នុងចិត្ត នោះព្រះអម្ចាស់ទ្រង់មិនព្រមស្តាប់ខ្ញុំទេ"(ទំនុកដំកើង ៦៦:១៨)។ ការអធិស្ឋាននេះ បង្រៀនយើងអំពីរបៀបដ៏ល្អបំផុតនៃការអធិស្ឋានដោយគូសចំណាំផ្លូវដែលនាំទៅរកឈើឆ្កាង និងទៅរកដួងព្រះទ័យនៃព្រះសង្គ្រោះនៃយើង។ ព្រះទ្រង់បានប្រទានដល់យើងនូវការអធិស្ឋានទាំងនេះ ដើម្បីបង្ហាញផ្លូវសម្រាប់ឲ្យយើងវិលត្រឡប់មករកព្រះអង្គវិញ។



"ដោយសេចក្តីមេត្តាករុណា ព្រះបានប្រទានដល់យើង នូវការអធិស្ឋានលន់តួបាប ដើម្បីបង្ហាញផ្លូវឲ្យយើងត្រឡប់មករកព្រះអង្គវិញ"។

## លំនាំនៃការអធិស្ឋាន

### *ព្រះអង្គស្គាល់ទូលបង្គំ គ្មានកន្លែងចន្លោះ តែព្រះអង្គនៅតែស្រឡាញ់ទូលបង្គំ*

តើដាវីឌទូលបង្គំនេះ និងទូលទ្រង់បានដូចម្តេចទៅទៀត? ដ្បិត ឱព្រះអម្ចាស់យេហូវ៉ាអើយ ទ្រង់ស្គាល់ទូលបង្គំ ជាអ្នកបំរើទ្រង់ហើយ។ ទ្រង់បានធ្វើការយ៉ាងធំទាំងនេះ ឲ្យទូលបង្គំជាបាវបំរើទ្រង់បានដឹង ដោយយល់ដល់ព្រះបន្ទូលនៃទ្រង់ទេ ហើយក៏តាមព្រះហឫទ័យទ្រង់ផង។ ដូច្នេះ ឱព្រះយេហូវ៉ាដ៏ជាព្រះអើយ ទ្រង់ធំណាស់ គ្មានណាឲ្យស្មើទ្រង់ឡើយ ហើយតាមគ្រប់ទាំងសេចក្តី ដែលត្រចៀកទូលបង្គំរាល់គ្នាបានឮ នោះក៏គ្មានព្រះឯណាក្រៅពីទ្រង់ដែរ (២សាំយ៉ូអែល ៧:២០-២២)។

***ដើម្បីបង្រៀនគេ អំពីសេចក្តីស្មោះត្រង់*** *និងសេចក្តីស្រឡាញ់ដែលមិនចេះចប់ដែលព្រះអង្គមានចំពោះរាស្ត្រព្រះអង្គ លោកហោរាហូសេបានព្យាយាមផ្សះផ្សាជាមួយភរិយាកំផិតរបស់គាត់ ទោះបីជានាងបានបោះបង់ចោលគាត់ និងកូនៗ ហើយត្រឡប់ទៅរកជីវិតជាស្ត្រីពេស្យា ក៏គាត់នៅតែទៅលោះនាងមកវិញ តែមិនមែនលោះមកធ្វើជាទាសករទេ តែធ្វើជាភរិយាជាទីស្រឡាញ់របស់គាត់វិញ។*

*ទោសកំហុសទូលបង្គំ ជាបន្ទុកដែលធ្ងន់ពេកក្រៃ*

ឱព្រះយេហូវ៉ាអើយ សូមកុំបន្ទោសទូលបង្គំ ក្នុងកាលដែលទ្រង់ខ្ញាល់ ក៏កុំវាយផ្ចាលទូលបង្គំ ដោយព្រះហឫទ័យក្តៅឡើយ។ ដ្បិតព្រួញរបស់ទ្រង់ជាប់គាំងនៅក្នុងខ្លួនទូលបង្គំ ហើយព្រះហស្តទ្រង់ក៏សង្កត់ទូលបង្គំខ្លាំងណាស់ផង។ គ្មានកន្លែងណាក្នុងរូបសាច់ទូលបង្គំ ដែលមិនឈឺនោះទេ ដោយព្រោះសេចក្តីខ្ញាល់របស់ទ្រង់ ក៏គ្មានសេចក្តីសុខនៅក្នុងឆ្អឹងទូលបង្គំដែរ។ ដ្បិតអំពើទុច្ចរិតរបស់ទូលបង្គំបានឡើងលិចក្បាលទូលបង្គំហើយ ក៏ដូចជាបន្ទុកយ៉ាងធ្ងន់ ដែលទូលបង្គំទ្រាំមិនបាន។ ទូលបង្គំនឹងលន់តួអំពើទុច្ចរិតរបស់ទូលបង្គំ ហើយនឹងឈឺចិត្តដោយព្រោះអំពើបាបរបស់ទូលបង្គំដែរ( ទំនុកដំកើង ៣៨:១-៤,១៨ )។



*"ឱព្រះយេហូវ៉ាអើយ ទូលបង្គំបាននឹករឭកដល់ សេចក្តីសង្គ្រោះរបស់ទ្រង់ ហើយក្រឹត្យវិន័យរបស់ទ្រង់ជាទីរីករាយដល់ទូលបង្គំ។ សូមអនុញ្ញាតឲ្យព្រលឹងទូលបង្គំរស់នៅ នោះនឹង បានសរសើរដល់ទ្រង់..."*

*ទូលបង្គំសូមបន្ទាបខ្លួន នៅចំពោះព្រះអង្គ*

ឱព្រះយេហូវ៉ាអើយ ចិត្តទូលបង្គំមិនមែនឆ្មើងឆ្មៃ ហើយភ្នែកទូលបង្គំក៏មិនប្រកាន់យស ទូលបង្គំមិនយកចិត្តទុកដាក់ក្នុងការដ៏ធំ ឬក្នុងដំណើរដែលអស្ចារ្យហួសល្បត់ទូលបង្គំឡើយ។ ទូលបង្គំបានរំងាប់ ហើយព្រលួងព្រលឹងទូលបង្គំជាស្រេច ដូចជាក្មេងដែលម្តាយបានផ្តាច់ដោះឲ្យ គឺដូចជាក្មេងដែលលែងដោះនៅជាមួយនឹងម្តាយអើ ព្រលឹងនៅក្នុងខ្លួនទូលបង្គំ ប្រៀបដូចជាកូនដែលលែងដោះហើយ( ទំនុកដំកើង ១៣១:១-២ )។

*ទូលបង្គំបានវង្វេងចេញ តែទូលបង្គំស្រឡាញ់ព្រះអង្គ។*

ឱព្រះយេហូវ៉ាអើយ សូមឲ្យសំរែករបស់ទូលបង្គំ បានចូលមកជិតនៅចំពោះទ្រង់ សូមប្រទានឲ្យទូលបង្គំមានយោបល់តាមព្រះបន្ទូលទ្រង់។ សូមឲ្យពាក្យអង្វររបស់ទូលបង្គំបានមកនៅចំពោះទ្រង់ សូមប្រោសទូលបង្គំឲ្យបានរួច តាមព្រះបន្ទូលទ្រង់ផង។ សូមអនុញ្ញាតឲ្យបបូរមាត់ទូលបង្គំ បានពោល ពាក្យសរសើរ ដ្បិតទ្រង់បង្រៀនអស់ទាំងបញ្ញត្តរបស់ទ្រង់ដល់ទូលបង្គំ។ សូមឲ្យអណ្តាតទូលបង្គំបានច្រៀងពីព្រះបន្ទូលទ្រង់ ពីព្រោះគ្រប់ទាំងសេចក្តីបង្គាប់របស់ទ្រង់សុទ្ធតែសុចរិតទាំងអស់។

សូមឲ្យព្រះហស្តទ្រង់បានប្រុងប្រៀបនឹងជួយទូលបង្គំ ព្រោះទូលបង្គំបានរើសយកបញ្ញត្តរបស់ទ្រង់។ ឱព្រះយេហូវ៉ាអើយ ទូលបង្គំបាននឹករឭកដល់ សេចក្តីសង្គ្រោះរបស់ទ្រង់ ហើយក្រឹត្យវិន័យរបស់ទ្រង់ជាទីរីករាយដល់ទូលបង្គំ។ សូមអនុញ្ញាតឲ្យព្រលឹងទូលបង្គំរស់នៅ នោះនឹង បានសរសើរដល់ទ្រង់ ហើយសូមឲ្យច្បាប់របស់ទ្រង់ជួយទូលបង្គំផង។ ទូលបង្គំបានវង្វេងទៅ ដូចជាចៀមបាត់បង់ សូមដេញរកអ្នកបំរើទ្រង់ផង ដ្បិតទូលបង្គំមិនភ្លេចសេចក្តីបង្គាប់របស់ទ្រង់ឡើយ។-ទំនុកដំកើង ១១៩:១៦៩-១៧៦

*ព្រះអង្គអើយ សូមសម្អាតទូលបង្គំឲ្យស្អាត។*

សូមជំរះទូលបង្គំដោយមែកហ៊ីសុប នោះទូលបង្គំនឹងបានជ្រះស្អាត សូមដុសលាងទូលបង្គំ នោះនឹងបានសជាងហិមៈ។ សូមឲ្យទូលបង្គំបានឮសេចក្តីអំណរ និងសេចក្តីរីករាយ នោះអស់ទាំងឆ្អឹងដែលទ្រង់បានបំបាក់បំបែក នឹងបានអរសប្បាយវិញ។ សូមបាំងព្រះភក្ត្រទ្រង់ចេញពីអំពើបាបរបស់ទូលបង្គំ ហើយលុបគ្រប់ទាំងអំពើទុច្ចរិតរបស់ទូលបង្គំចេញ។-ទំនុកដំកើង ៥១:៧-៩

*"ឯទិសខាងកើតនៅឆ្ងាយពីទិសខាងលិចយ៉ាងណា ទ្រង់បានដកយកអស់ទាំងការល្មើសនៃយើង ឲ្យឃ្លាតឆ្ងាយពីយើងយ៉ាងនោះដែរ"(ទំនុកដំកើង ១០៣:១២)។*

# សូមអធិស្ឋាន ដោយផ្តើមដោយពាក្យ តាមលំនាំខាងក្រោម

*ទូលបង្គំមិនសក្តិសមនឹងទទួលសេចក្តីសប្បុរសរបស់ព្រះអង្គទេ*

ទូលបង្គំមិនគួរឲ្យបានអស់ទាំងសេចក្តីសប្បុរស និងអស់ទាំងសេចក្តីស្មោះត្រង់ដែលទ្រង់បានផ្តល់មកទូលបង្គំជាអ្នកបំរើទ្រង់ទេ។-លោកុប្បត្តិ ៣២:១០

*សូមជួយទូលបង្គំ អត់ទោស ហើយសង្គ្រោះទូលបង្គំ ដើម្បីថ្វាយសិរីល្អដល់ព្រះអង្គ!*

ឱព្រះដ៏ជួយសង្គ្រោះយើងខ្ញុំអើយ សូមជួយយើងខ្ញុំ ដោយយល់ដល់សិរីល្អនៃព្រះនាមទ្រង់ សូមប្រោសឲ្យយើងខ្ញុំរួច ហើយអត់ទោសអំពើបាប របស់យើងខ្ញុំផង ដោយយល់ដល់ព្រះនាមទ្រង់។-ទំនុកដំកើង ៧៩:៩

*ទូលបង្គំប្រែចិត្តចេញពីការបះបោររបស់ទូលបង្គំ*

ឱព្រះយេហូវ៉ាអើយ សូមទតមើល ដ្បិតខ្ញុំម្ចាស់ មានសេចក្តីវេទនា ចិត្តខ្ញុំម្ចាស់ទុរន់

ទុក ចិត្តខ្ញុំម្ចាស់ក្រឡាប់ចុះនៅក្នុងខ្លួន ពីព្រោះខ្ញុំម្ចាស់បានបះបោរជាខ្លាំងហើយ។-បរិទេវ ១:២០

*សូមមានសេចក្ដីមេត្តាចំពោះទូលបង្គំ*
ឱព្រះអង្គអើយ សូមទ្រង់មេត្តាអត់ទោសដល់ទូលបង្គំ ដែលជាអ្នកមានបាបផង។-លូកា ១៨:១៣



*ទី៣*

# ការអធិស្ឋានសម្រាប់តម្រូវការប្រចាំថ្ងៃ

ជួនកាលខ្ញុំប្រញាប់ ចូលទៅក្នុងព្រះវត្តមានព្រះអង្គ ដោយមានសេចក្តីត្រូវការជាច្រើន សម្រាប់ទូលថ្វាយព្រះអង្គ។ ទោះបីជាព្រះបន្ទូលព្រះអង្គ លើកទឹកចិត្តយើងឲ្យ "មកដល់បល្ល័ង្កនៃព្រះគុណ ដោយក្លាហាន"(ហេព្រើ ៤:១៦)ក៏ដោយ ក៏មានពេលខ្លះ ខ្ញុំឆ្ងល់ថា តើខ្ញុំបានចូលបល្ល័ង្កព្រះអង្គ ដោយទូលសូមព្រះអង្គច្រើនពេកឬទេ? បើពេលបច្ចុប្បន្ន ចិត្តរបស់ខ្ញុំគិតតែអំពីរបស់ដែលនៅក្នុងលោកិយនេះ តើពេលនៅស្ថានសួគ៌ ការទូលសូមយ៉ាងដូចនេះ មានលក្ខណៈដូចម្តេចដែរ...។

ខ្ញុំអាចស្រមៃថា ព្រះវរបិតាទ្រង់គង់លើបល្ល័ង្កនៅទីខ្ពស់ ហើយបានដំកើងឡើង ឯរំភាយព្រះពស្ត្រទ្រង់សាយមកពេញក្នុងព្រះវិហារ នៅពីលើទ្រង់មានពួកសេរភីម គ្រប់គ្នាមានស្លាប៦ ក៏បាំងមុខដោយស្លាប២ ថ្វាយបង្គំនៅចំពោះមុខព្រះអម្ចាស់(អេសាយ ៦:១-២)។ ហើយខ្ញុំក៏បានដើរចូលមក ក្នុងនាមជាកូន ដោយមិនបានគោះទ្វារ ហើយក៏ទូលថ្វាយគ្រប់ទាំងអ្វីៗដែលខ្ញុំចង់បាន។

ការធ្វើដូចនេះដូចជាមិនទំនងទេ ប៉ុន្តែ រឿងនេះគឺបង្ហាញពីព្រះគុណរបស់ព្រះ។ ខ្ញុំជាកូន គឺកូននៃព្រះវរបិតា ដែលបានសង្គ្រោះ ដោយសារជំនឿលើព្រះរាជបុត្រា ព្រះអង្គដែលបានសុគតនៅលើឈើឆ្កាង(យ៉ូហាន ១:១០-១២)។ ខ្ញុំអាចចូលមកដោយចិត្តក្លាហាន ដោយគ្មានការភ័យខ្លាច ព្រោះព្រះអង្គជា "អ័ប្បា ព្រះវរបិតា"(រ៉ូម ៨:១៥)។ ព្រះអង្គជ្រាបអំពីសេចក្តីត្រូវការ ដែលខ្ញុំមានប្រចាំថ្ងៃ ហើយយកព្រះទ័យទុកដាក់យ៉ាងខ្លាំង ចំពោះសេចក្តីត្រូវការទាំងនោះ។ ព្រះអង្គមិនខ្វល់ថា ខ្ញុំបានរៀប

**ព្រះយេស៊ូវមិនគ្រាន់តែបាននាំមកនូវការផ្សះផ្សា**រវាងព្រះ និងមនុស្សជាតិប៉ុណ្ណោះទេ តែថែមទាំងបានប្រទាននូវអត្តសញ្ញាណថ្មី ដល់អ្នកដែលទទួលជឿព្រះអង្គផងដែរ។ យើងមិនមែនជាអ្នកក្រៅ ឬជាខ្មាំងសត្រូវទៀតទេ តែក្នុងព្រះគ្រីស្ទ យើងជាកូនប្រុស និងកូនស្រីរបស់ព្រះអង្គ(កូឡូស ១:២០-២២)។



*"ការអធិស្ឋានអំពីសេចក្ដីត្រូវការប្រចាំថ្ងៃ ជួយឲ្យយើងមានទស្សនៈត្រឹមត្រូវ។ គឺមិនគ្រាន់តែជាការទូលសូមសម្រាប់ការអ្វីដែលចាំបាច់សម្រាប់ជីវិតនៅលើផែនដីប៉ុណ្ណោះទេ តែក៏សម្រាប់បំពេញសេចក្ដីត្រូវការដ៏សំខាន់បំផុត ដែលជាការត្រូវការទំនាក់ទំនងដែលលូតលាស់ ជាមួយព្រះវរបិតាដែលគង់នៅស្ថានសួគ៌។"*

ពាក្យសម្ដីបានប្រឹតប្រៀនយ៉ាងណាឡើយ តែព្រះអង្គខ្វល់ អំពីសណ្ឋាននៃចិត្តរបស់ខ្ញុំ។ ហើយចិត្តរបស់ខ្ញុំកាន់តែពេញវ័យប៉ុណ្ណា នោះចិត្តនោះក៏ត្រូវតាមបំណងព្រះទ័យព្រះអង្គកាន់តែខ្លាំងយ៉ាងនេះដែរ។

ព្រះទ្រង់ចង់ឲ្យយើងមានការលូតលាស់ ហើយមាន "ភាពពេញវ័យ"(ហេព្រើ ៦:១) ក្នុងទំនាក់ទំនងជាមួយព្រះអង្គ។ លោកអេនឌ្រូ មូររេយ(Andrew Murray) បានពន្យល់ថា

> ពីដំបូង ក្មេងតូចប្រហែលជាសូមអ្វីដែលវាត្រូវការ ពីឪពុកវា ហើយមិនយូរប៉ុន្មានវាក៏បានរៀននិយាយថា "សូមលោកឪពុកឲ្យប្អូនស្រីខ្លះដែរ"។ ប៉ុន្តែ កូនប្រុសដែលពេញវ័យគិតពីប្រយោជន៍របស់ឪពុក និងមើលការខុសត្រូវមុខជំនួញរបស់ឪពុក ហើយគាត់សុំឪពុកជាច្រើនសណ្ឋិកជាង ហើយក៏បានទទួលអ្វីទាំងអស់ដែលបានសុំផង។

ការអធិស្ឋានអំពីសេចក្ដីត្រូវការប្រចាំថ្ងៃ ជួយឲ្យយើងមានទស្សនៈត្រឹមត្រូវ។ គឺមិនគ្រាន់តែជាការទូលសូមសម្រាប់ការអ្វី ដែលចាំបាច់សម្រាប់ជីវិតនៅលើផែនដីប៉ុណ្ណោះទេ តែក៏សម្រាប់បំពេញសេចក្ដីត្រូវការដ៏សំខាន់បំផុតដែលជាការត្រូវការទំនាក់ទំនង

ដែលលូតលាស់ ជាមួយព្រះវរបិតាដែលគង់នៅស្ថានសួគ៌។ ព្រះយេស៊ូវបានឲ្យយើងយកការនេះជាអាទិភាព សម្រាប់ការរស់នៅ ហើយបានមានបន្ទូលបង្គាប់យើងយ៉ាងច្បាស់ថា "ចូរស្វែងរកនគរ និងសេចក្ដីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះ នឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង"(ម៉ាថាយ ៦:៣៣)។

ព្រះទ្រង់សព្វព្រះទ័យឲ្យយើងទូលថ្វាយអំពីសេចក្ដីត្រូវការប្រចាំថ្ងៃ ដល់ព្រះអង្គ ដោយសេចក្ដីជំនឿ និងដោយការរំពឹងគិត ដើម្បីឲ្យយើងរស់នៅ ដោយពឹងផ្អែកទៅលើព្រះអង្គ ដោយសេចក្ដីស្រឡាញ់ និងស្គាល់ព្រះពរ ដែលទទួលបានពីការធ្វើតាមបំណងព្រះទ័យព្រះអង្គ។ ព្រះអង្គជា "ព្រះអម្ចាស់ជីវិត"(កិច្ចការ ៣:១៥) ហើយយើងមានជីវិតរស់ ដើម្បីព្រះអង្គ ហើយដោយសារព្រះអង្គ។ ព្រះអង្គសព្វព្រះទ័យនឹងប្រទានពរយើង ហើយនាំយើងចូលទៅជិតព្រះអង្គ ដោយសេចក្ដីស្រឡាញ់ ដែលប្រទានជីវិតដល់វិញ្ញាណយើង។ ព្រះអង្គជាព្រះពរដ៏ធំបំផុត។

*ការអធិស្ឋានមិនមែនជាការរកស៊ីដោះដូរទេ។ បើយើងអធិស្ឋាន ដោយសារតែយើងចង់បានអ្វីពីព្រះអង្គ នោះគឺខុសហើយ។ ការអធិស្ឋានជាទំនាក់ទំនងដ៏ស្និទ្ធស្នាលជាមួយព្រះ។ ពេលដែលយើងអធិស្ឋាន ក្នុងពេលមានសេចក្ដីត្រូវការខ្លាំងបំផុត យើងអាចជួបព្រះអង្គ ហើយទទួលព្រះវត្តមានព្រះអង្គ។*

## លំនាំនៃការអធិស្ឋាន

### *ព្រះអង្គជាអ្នកគង្វាលខ្ញុំ*

ព្រះយេហូវ៉ាទ្រង់ជាអ្នកគង្វាលខ្ញុំ ខ្ញុំនឹងមិនខ្វះអ្វីសោះ ទ្រង់ឲ្យខ្ញុំដេកសំរាកនៅទីមានស្មៅខៀវខ្ចីទ្រង់នាំខ្ញុំទៅក្បែរមាត់ទឹកដែលហូរគ្រឿនៗ ទ្រង់កែព្រលឹងខ្ញុំឡើងវិញ ទ្រង់នាំខ្ញុំទៅតាមផ្លូវសុចរិត ដោយយល់ដល់ព្រះនាមទ្រង់។ អើ ទោះបើទូលបង្គំដើរកាត់ច្រកភ្នំនៃម្លប់សេចក្ដីស្លាប់ក៏ដោយ គង់តែមិនខ្លាចសេចក្ដីអាក្រក់ណាឡើយ ដ្បិតទ្រង់គង់នៅជាមួយនឹងទូលបង្គំ ព្រនង់ ហើយនឹងដំបងរបស់ទ្រង់កំសាន្ដចិត្តទូលបង្គំ ទ្រង់រៀបតុនៅមុខទូលបង្គំ ចំពោះពួកខ្មាំងសត្រូវផង ទ្រង់ចាក់ប្រេងលាបលើក្បាលទូលបង្គំ ពែងនៃទូលបង្គំក៏ពេញហៀរ។ ប្រាកដជាសេចក្ដីសប្បុរស និងសេចក្ដីមេត្តាករុណា នឹងជាប់តាមខ្ញុំ រាល់តែថ្ងៃ ដរាបដល់អស់១ជីវិតខ្ញុំ ហើយខ្ញុំនឹង

នៅក្នុងដំណាក់នៃព្រះយេហូវ៉ា ជារៀងដរាបទៅ។ ទំនុកដំកើង ២៣:១-៦

### *ព្រះអង្គបានផ្គត់ផ្គង់ទូលបង្គំ កាលពីមុន*

ឱព្រះអង្គអើយ កាលទ្រង់បានយាងចេញនាំមុខ រាស្ត្រទ្រង់ទៅ នៅវេលាដែលទ្រង់បានយាងកាត់ទីហោស្ថាន។ នោះផែនដីក៏ញ័រ ហើយមេឃក៏ធ្លាក់មកជាភ្លៀង នៅចំពោះទ្រង់ ភ្នំស៊ីណាយក៏កក្រើកញ័រ នៅចំពោះព្រះ គឺជាព្រះ នៃសាសន៍អ៊ីស្រាអែល។ ឱព្រះអង្គអើយ ទ្រង់បានបង្អុរភ្លៀងជាបរិបូរ ក៏បានតាំងមរដកទ្រង់ដែលហេវនោះ ឲ្យជាប់មាំមួនឡើង។ ពួកកងរបស់ទ្រង់បានអាស្រ័យនៅស្រុកនោះ ឱព្រះអង្គអើយ ទ្រង់បានផ្គត់ផ្គង់ដល់ពួកមនុស្សក្រីក្រ ដោយសេចក្តីសប្បុរសនៃទ្រង់។-ទំនុកដំកើង ៦៨:៧-១០

*ក្នុងបទគម្ពីរ យ៉ូស្វេ ៤:១-១១ ព្រះអម្ចាស់បានបង្គាប់លោកយ៉ូស្វេឲ្យសាងសង់ទីរំឭក ដោយប្រើថ្ម ដើម្បីបង្រៀនមនុស្សជំនាន់ក្រោយ អំពីសេចក្តីស្មោះត្រង់របស់ព្រះ។*

### *ជីវិតទាំងអស់ពឹងផ្អែកលើព្រះអង្គ*

ឱព្រះយេហូវ៉ាអើយ អស់ទាំងស្នាដៃរបស់ទ្រង់មាន ច្រើនប្រការណាស់ហ្ន៎ ទ្រង់បានធ្វើទាំងអស់ដោយប្រាជ្ញា ផែនដីបានពេញដោយរបស់ដែលទ្រង់បង្កើត។ នុ៎ះន៏សមុទ្រដ៏ធំ ហើយទូលាយ នៅក្នុងទឹកនោះមានរបស់រវើកឥតគណនា ជាសត្វទាំងតូចទាំងធំ។ ក៏មាននាវាបើកទៅមក ហើយមានសត្វធំសំបើម ដែលទ្រង់ បានបង្កើតឲ្យលេងក្នុងទឹក។ គ្រប់សត្វទាំងនោះសង្ឃឹមចាំតែទ្រង់ ឲ្យទ្រង់បានប្រទានចំណីដល់វាតាមត្រូវពេល។ ទ្រង់ក៏ប្រទានឲ្យ ហើយវាទទួលយក កាលទ្រង់លាព្រះហស្តទៅ នោះវាបានឆ្អែតដោយរបស់ល្អ។ កាលទ្រង់លាក់ព្រះភក្ត្រ នោះវាបានថប់ព្រួយវិញកាលទ្រង់ដកយកដង្ហើមចេញ នោះវាក៏ស្លាប់ ហើយត្រឡប់ទៅជាធូលីដីវិញ។ ទ្រង់ចាត់ព្រះវិញ្ញាណរបស់ទ្រង់ទៅ នោះវាកើតឡើង ទ្រង់កែប្រែផែនដីឡើងជាថ្មី។ -ទំនុកដំកើង ១០៤:២៣-៣០

### *ព្រះអង្គគង់នៅជាមួយទូលបង្គំ ទោះជាទូលបង្គំទៅទីណាក៏ដោយ*

តើទូលបង្គំនឹងទៅឯណា ឲ្យរួចពីព្រះវិញ្ញាណទ្រង់ តើនឹងរត់ទៅឯណា ឲ្យរួចពីព្រះ

ភ័ក្ត្រទ្រង់។ ទោះបើទូលបង្គំនឹងឡើងទៅឯស្ថានសួគ៌ ក៏មានទ្រង់សណ្ឋិតនៅទីនោះ ទោះបើទូលបង្គំនឹងរៀបដំណេកនៅស្ថានឃុំ ព្រលឹងមនុស្សស្លាប់ នោះក៏ឃើញមានទ្រង់សណ្ឋិតនៅដែរ។ ទោះបើទូលបង្គំនឹងយកស្លាបនៃបច្ចូសកាល ហោះទៅនៅឯទីបំផុតនៃសមុទ្រ។ គង់តែព្រះហស្តទ្រង់នឹងនាំទូលបង្គំនៅទីនោះ ហើយព្រះហស្តស្តាំទ្រង់នឹងក្តាប់ទូលបង្គំដែរ។ បើទូលបង្គំថា សេចក្តីងងឹតនឹងគ្របបាំង ទូលបង្គំជាប្រាកដ ហើយពន្លឺដែលនៅជុំវិញទូលបង្គំនឹងត្រឡប់ទៅជាយប់វិញ។ ដូច្នេះទាំងសេចក្តីងងឹតនោះឯងមិនលាក់ពីទ្រង់ឡើយ ទោះទាំងយប់ក៏ភ្លឺដូចជាពេលថ្ងៃដែរ ឯសេចក្តីងងឹត និងពន្លឺភ្លឺ នោះស្មើគ្នានៅចំពោះទ្រង់។-ទំនុកដំកើង ១៣៨:៧-១២



*"តើទូលបង្គំនឹងទៅឯណា ឲ្យរួចពីព្រះវិញ្ញាណទ្រង់ តើនឹងរត់ទៅឯណា ឲ្យរួចពីព្រះភក្ត្រទ្រង់"*

## លោកអ្នកអាចអធិស្ឋាន ដោយផ្តើមដោយពាក្យ តាមលំនាំខាងក្រោម

*សូមនឹកចាំអំពីតម្រូវការរបស់ទូលបង្គំ*

ឯទូលបង្គំៗក្រីក្រ ហើយទុគ៌ត ប៉ុន្តែព្រះអម្ចាស់ទ្រង់នឹកដល់ទូលបង្គំដែរ ទ្រង់ជាជំនួយ ហើយជាអ្នកប្រោសឲ្យទូលបង្គំរួចផង ឱព្រះនៃទូលបង្គំអើយ សូមកុំបង្អង់ឡើយ។-ទំនុកដំកើង ៤០:១៧

*ព្រះអង្គអត់ទោសបាបឲ្យទូលបង្គំ ហើយប្រទានក្តីអំណរ*

អស់ទាំងសេចក្តីទុច្ចរិតតែងតែឈ្នះទូលបង្គំ ឯការរំលងរបស់យើងខ្ញុំ នោះទ្រង់នឹងជំរះចោលចេញ។ មានពរហើយ អ្នកណាដែលទ្រង់រើស ហើយនាំមកនៅចំពោះទ្រង់ ដើម្បីឲ្យបានអាស្រ័យនៅក្នុងព្រះលានទ្រង់ យើងខ្ញុំនឹងបានស្កប់ចិត្តដោយសេចក្តីលំអនៃដំណាក់ទ្រង់ គឺជាព្រះវិហារដ៏បរិសុទ្ធរបស់ទ្រង់។-ទំនុកដំកើង ៦៥:៣-៤

*សូមឆ្លើយតបការអធិស្ឋានរបស់ទូលបង្គំ ហើយមើលថែរទូលបង្គំ*

ឱព្រះយេហូវ៉ាអើយ សូមឆ្លើយតបមកទូលបង្គំផង ដ្បិតសេចក្តីសប្បុរសរបស់ទ្រង់ល្អណាស់ហើយ សូមបែរមកឯទូលបង្គំ តាមសេចក្តីមេត្តាករុណា ដ៏បរិបូររបស់ទ្រង់។-ទំនុកដំកើង ៦៩:១៦



*ទី៤*

# អធិស្ឋានសូមការដឹកនាំ និងទិសដៅ

ព្រះគម្ពីរបានចែងអំពីការដែលព្រះដឹកនាំរាស្ត្រព្រះអង្គ ឲ្យឆ្លងកាត់កាលៈទេសៈគ្រប់ប្រភេទ។ ព្រះអង្គនាំមុខរាស្ត្រអ៊ីស្រាអែល ក្នុងវាលរហោស្ថាន ដោយដឹកនាំពួកគេ ដោយបង្គោលពពក ពេលថ្ងៃ និងបង្គោលភ្លើង ពេលយប់ (និក្ខមនំ ១៣:២១)។ ព្រះអង្គបានចាត់ទេវតា ឲ្យដឹកនាំលោកឡុត និងក្រុមគ្រួសារគាត់ ចេញពីក្រុងសូដុំម(លោកុប្បត្តិ ១៩:១៦) ហើយនាំលោកពេត្រុស ចេញពីគុក (កិច្ចការ ១២:៧)។ ស្តេចដាវីឌ និងលោកអេសាយបានពិពណ៌នាអំពីព្រះ ដោយចិត្តឆេះឆួលថា ព្រះអង្គជាអ្នកគង្វាល(ទំនុកដំកើង ២៣ អេសាយ ៤០:១១) ហើយលោកមីកាបានថ្លែងទំនាយអំពីព្រះយេស៊ូវថា "អ្នកនោះនឹងឈរឡើងឃ្វាលហ្វូងចៀមរបស់ខ្លួន ដោយសារឥទ្ធិឫទ្ធិនៃព្រះយេហូវ៉ា និងឫទ្ធានុភាពរបស់ព្រះនាមព្រះយេហូវ៉ា"(មីកា ៥:៤)។ ព្រះគម្ពីរបានកំសាន្តចិត្ត ដោយបកស្រាយច្បាស់ៗថា ព្រះវរបិតានៃយើងដែលគង់នៅស្ថានសួគ៌ យកព្រះទ័យទុកដាក់ ចំពោះចំណុចដ៏តូចបំផុតនៃជីវិតយើង។

មានបទគម្ពីរជាច្រើន ដែលបានចែងអំពីការដឹកនាំរបស់ព្រះ ដែលផ្តល់ទិសដៅឲ្យយើង តែយើងមិនសូវអធិស្ឋានសូមការដឹកនាំ និងទិសដៅពីព្រះអង្គទេ។ យើងត្រូវដឹងថា យើងអាចទទួលការដឹកនាំរបស់ព្រះ តាមរយៈទំនាក់ទំនងជាមួយព្រះអង្គ

អ្នកគង្វាលយើងចង់ឲ្យចំណីយើង បើយើងនៅក្នុងព្រះហស្តព្រះអង្គ លើកផ្ទាប់នៅព្រះឱរ៉ា ហើយដឹកនាំយើង ដោយការថ្នាក់ថ្នម(អេសាយ ៤០:១១)។ យើងត្រូវតែ "អធិស្ឋានជាប់ជានិច្ច"(១ថែស្សាឡូនិច ៥:១៧) ព្រោះយើងមិនអាចស្គាល់ការដឹកនាំរបស់ព្រះ ក្នុងជីវិតយើងបានឡើយ បើសិនជាគ្មានការអធិស្ឋានទេនោះ។ ការអធិស្ឋានសូមការដឹកនាំ និងទិសដៅ តាមលំនាំក្នុងព្រះគម្ពីរ ជាការប្រកបស្និទ្ធស្នាលជាមួយព្រះ គឺមិនខុសពីការអធិស្ឋានអំពីសេចក្តីត្រូវការប្រចាំថ្ងៃឡើយ។ ការអធិស្ឋានដែលជាការប្រកបជាមួយព្រះ មិនគ្រាន់តែស្វែងរកបំណងព្រះទ័យព្រះប៉ុណ្ណោះទេ តែថែមទាំងស្វែងរកព្រះភ័ក្រព្រះអង្គផងដែរ។ ការអធិស្ឋានដែលជាការប្រកបជាមួយព្រះ ជួយឲ្យយើងស្វែងរកការដឹកនាំរបស់ព្រះ និងឆ្លើយតបចំពោះព្រះអង្គ ដោយការស្តាប់បង្គាប់ និងស្រឡាញ់កាន់តែជ្រាលជ្រៅ។ ព្រះទ្រង់បានរំឭករាស្ត្រព្រះអង្គ តាមរយៈលោកអេសាយថា "ឯងរាល់គ្នានឹងបានសង្គ្រោះដោយវិលមកវិញ ហើយផ្អាកសំរាក ឯងរាល់គ្នានឹងមានកំឡាំង ដោយនៅតែស្ងៀម ហើយមានសេចក្តីទុកចិត្ត"(អេសាយ ៣០:១៥)។ យើងមានកម្លាំងជាថ្មី ពេលដែលយើងអធិស្ឋាន ហើយតមអត់ និងរង់ចាំ នៅចំពោះព្រះអង្គ តាមព្រះបន្ទូល។

ការល្បួងដែលយើងច្រើនតែជួបប្រទះ គឺការល្បួងដែលនាំឲ្យយើងចង់ដឹកនាំជីវិតខ្លួនឯង ហើយសូមឲ្យព្រះអង្គប្រទានពរយើង។ តែព្រះអង្គមិនសព្វព្រះទ័យឲ្យយើងធ្វើដូចនេះទេ។ លោកអូសវល ឆេមប័រ(Oswald Chambers) បានសង្កេតឃើញថា គ្រីស្ទបរិស័ទជាច្រើនដែលអធិស្ឋានទូលសូមអ្វីៗពីព្រះ គឺមិនខុសពីក្មេងៗដែលយកគ្រឿងលេងមកចោលរាយប៉ាយនៅមុខឪពុកវា ដោយនិយាយថា "វាខូចហើយ កូនលេងវាមិនកើតទេ សូមប៉ាទិញគ្រឿងលេងផ្សេងទៀតឲ្យខ្ញុំមក"។ ក្នុងចំណោមគ្រីស្ទបរិស័ទ១ពាន់នាក់ មានតែម្នាក់ទេ ដែលដូចជាក្មេងដ៏ល្អម្នាក់ ដែលនិយាយទៅកាន់ឪពុកខ្លួនថា "សូមប៉ាជួសជុលវា ឲ្យខ្ញុំមើលផង"។

ស្តេចដាវីឌបានអធិស្ឋានថា "ឱព្រះយេហូវ៉ាអើយ ទូលបង្គំសូមលើក ព្រលឹងថ្វាយដល់ទ្រង់ ... សូមបង្ហាញអស់ទាំងផ្លូវរបស់ទ្រង់ ដល់ទូលបង្គំ សូមបង្រៀនទូលបង្គំក្នុងផ្លូវច្រករបស់ទ្រង់។ សូមនាំ ហើយបង្រៀនទូលបង្គំ ក្នុងសេចក្តីពិតរបស់ទ្រង់ផង ដ្បិតទ្រង់ជាព្រះដ៏ជួយសង្គ្រោះទូលបង្គំ ទូលបង្គំសង្ឃឹមដល់ទ្រង់ជារាបរាល់ថ្ងៃ"(ទំនុកដំកើង ២៥:១,៤-៥)។ នៅក្នុងការអធិស្ឋានសូមការដឹកនាំ និងទិសដៅតាមលំនាំព្រះគម្ពីរ យើងត្រូវចាំថា ព្រះទ្រង់សំខាន់ជាងការអ្វីដែលយើងទូលសូមពីព្រះអង្គ ទោះបីជាការទូលសូមនោះមានភាពបន្ទាន់យ៉ាងណាក្តី។

អ្នកគង្វាលនៃយើងចង់ឲ្យយើងនៅក្បែរព្រះអង្គជាពិសេស ពេលដែលយើងមិនដឹងជាត្រូវទៅតាមផ្លូវមួយណា។ ខាងក្រោមនេះ ជាលំនាំនៃការអធិស្ឋានដែលជួយឲ្យយើងចូលទៅជិតព្រះអង្គ។



*"ការអធិស្ឋានសូមការដឹកនាំ និងទិសដៅ តាមលំនាំក្នុងព្រះគម្ពីរ ជាការប្រកបស្និទ្ធស្នាលជាមួយព្រះ គឺមិនខុសពីការអធិស្ឋានអំពីសេចក្តីត្រូវការប្រចាំថ្ងៃឡើយ។ ការអធិស្ឋានដែលជាការប្រកបជាមួយព្រះ មិនគ្រាន់តែស្វែងរកបំណងព្រះទ័យព្រះប៉ុណ្ណោះទេ តែថែមទាំងស្វែងរកព្រះភ័ក្រព្រះអង្គផងដែរ"។*

## លំនាំនៃការអធិស្ឋាន

### *សូមបង្ហាញទូលបង្គំនូវផ្លូវដែលត្រឹមត្រូវ*

ឱព្រះយេហូវ៉ាអើយ ទូលបង្គំសូមលើកព្រលឹងថ្វាយដល់ទ្រង់។ ប៉ុន្តែអស់អ្នកដែលមានចិត្តសង្ឃឹមដល់ទ្រង់ នោះមិនត្រូវខ្មាសឡើយ គឺពួកអ្នកប្រព្រឹត្តក្បត់ដោយឥតហេតុ ដែលត្រូវខ្មាសវិញ។ ឱព្រះយេហូវ៉ាអើយ សូមបង្ហាញអស់ទាំងផ្លូវរបស់ទ្រង់ ដល់ទូលបង្គំ សូមបង្រៀនទូលបង្គំក្នុងផ្លូវច្រករបស់ទ្រង់។ សូមនាំហើយបង្រៀនទូលបង្គំ ក្នុងសេចក្តីពិតរបស់ទ្រង់ផង ដ្បិតទ្រង់ជាព្រះដ៏ជួយសង្គ្រោះទូលបង្គំ ទូលបង្គំសង្ឃឹមដល់ទ្រង់ជារាបរាល់ថ្ងៃ។-ទំនុកដំកើង ២៥:១,៣-៥

### *សូមចាត់ពន្លឺព្រះអង្គឲ្យនាំផ្លូវទូលបង្គំ*

ឱសូមផ្សាយពន្លឺ និងសេចក្តីពិត ចេញមកនាំមុខទូលបង្គំ ដើម្បីឲ្យបាននាំទូលបង្គំទៅឯភ្នំបរិសុទ្ធ ហើយក្នុងព្រះវិហារនៃទ្រង់។ នោះទូលបង្គំនឹងទៅឯអាសនានៃព្រះ គឺដល់ព្រះដ៏ជាសេចក្តីអំណរ និងជាសេចក្តីរីករាយរបស់ទូលបង្គំ ឱព្រះអង្គដ៏ជាព្រះនៃទូលបង្គំអើយ ទូលបង្គំនឹងសរសើរដល់ទ្រង់ដោយចាប៉ស៊ីង!-ទំនុកដំកើង ៤៣:៣-៤

### *សូមដឹកនាំផ្លូវទូលបង្គំ ដោយព្រះបន្ទូលព្រះអង្គ*

សេចក្តីបន្ទាល់របស់ទ្រង់សុទ្ធតែអស្ចារ្យ ហេតុនោះបានជាព្រលឹងនៃទូលបង្គំគោរពកាន់តាម។ ការបើកសំដែងព្រះបន្ទូលទ្រង់ នោះផ្សាយពន្លឺចេញ ក៏ធ្វើឲ្យមនុស្ស

ឆោតល្ងង់មានយោបល់។ ទូលបង្គំបានហាមាត់ដកដង្ហើមធំ ដោយនឹករឭកដល់សេចក្ដីបង្គាប់របស់ទ្រង់។ សូមទ្រង់បែរមកមានសេចក្ដីអាណិតមេត្តា ដល់ទូលបង្គំ ដូចជាទ្រង់តែងធ្លាប់ធ្វើដល់អស់អ្នក ដែលស្រឡាញ់ព្រះនាមទ្រង់។ សូមតាំងជំហាននៃទូលបង្គំឲ្យដើរតាមព្រះបន្ទូលទ្រង់ សូមកុំឲ្យសេចក្ដីទុច្ចរិតណាមានអំណាច លើទូលបង្គំឡើយ។ សូមលោះទូលបង្គំឲ្យរួចពីការសង្កត់សង្កិន របស់មនុស្ស នោះទូលបង្គំនឹងកាន់តាមបញ្ញត្តទ្រង់។ សូមឲ្យព្រះភក្ត្រទ្រង់ភ្លឺមកលើអ្នកបំរើទ្រង់ ហើយបង្រៀនអស់ទាំងបញ្ញត្តទ្រង់ដល់ទូលបង្គំផង។ ទឹកភ្នែកទូលបង្គំហូររហាម ពីព្រោះគេមិនកាន់តាមក្រឹត្យវិន័យរបស់ទ្រង់។ -ទំនុកដំកើង ១១៩:១២៩-១៣៦

*"**មានពរហើយ** អ្នកណាដែលមិនដើរតាមដំបូន្មាន របស់មនុស្សអាក្រក់ ក៏មិនឈរនៅក្នុងផ្លូវរបស់មនុស្សមានបាប ឬអង្គុយនៅជាមួយនឹងពួកមនុស្សដែលមើលងាយ។ អ្នកនោះត្រេកអរតែនឹងក្រឹត្យវិន័យរបស់ព្រះយេហូវ៉ាវិញ ក៏រំពឹងគិតក្នុងក្រឹត្យវិន័យទ្រង់ទាំងយប់ទាំងថ្ងៃដែរ"( ទំនុកដំកើង ១:១-២ )*

## លោកអ្នកអាចអធិស្ឋាន ដោយផ្ដើមដោយពាក្យ តាមលំនាំខាងក្រោម

***ឱព្រះអម្ចាស់ សូមបង្ហាញព្រះវត្តមានព្រះអង្គ***

លោកទូលឆ្លើយថា សូមទ្រង់មេត្តាបើកឲ្យទូលបង្គំឃើញសិរីល្អទ្រង់ផង។-និក្ខមនំ ៣៣:១៨

***សូមបង្ហាញទូលបង្គំ ពីរបៀបបង្កើនសេចក្ដីជំនឿ***

សូមទ្រង់ចំរើនសេចក្ដីជំនឿដល់យើងខ្ញុំទៀតផង។-លូកា ១៧:៥

***តើទូលបង្គំគួរធ្វើដូចម្ដេច?***

ព្រះអម្ចាស់អើយ តើត្រូវឲ្យទូលបង្គំធ្វើដូចម្ដេច?-កិច្ចការ ២២:១០



*ទី៥*

# អធិស្ឋាន ដើម្បីពោលពាក្យអរព្រះគុណ

បើគ្មានព្រះយេស៊ូវទេ តើអ្នកនឹងទៅជាយ៉ាងណា? ចូរចំណាយពេលមួយភ្លែត ដើម្បីគិតអំពីសំណួរនេះ។ ត្រង់ចំណុចនេះ បទគម្ពីរអេភេសូរ ២:១២ បានឆ្លើយតបចំពោះសំណួរនេះ ជាសរុបបានយ៉ាងប្រសើរថា បើគ្មានព្រះ យើងគ្មានសង្ឃឹមអ្វីទេ។ បើគ្មានព្រះយេស៊ូវទេ នោះយើងប្រាកដជាបាត់បង់អស់កល្បជានិច្ច ដោយគ្មានក្តីសង្ឃឹម។

យើងមិនអាចអរព្រះគុណព្រះ ឲ្យបានគ្រប់គ្រាន់ឡើយ ហើយការអធិស្ឋាន "អរព្រះគុណ" តាមលំនាំព្រះគម្ពីរ ធ្វើឲ្យយើងមានការដឹងគុណព្រះកាន់តែខ្លាំង ហើយបើកភ្នែកយើងឲ្យមើលទៅ "សិរីល្អដ៏ប្រសើរក្រៃលែងនៃមរដកទ្រង់ ក្នុងពួកបរិសុទ្ធ" (អេភេសូរ ១:១៨)។ ការអធិស្ឋានអរព្រះគុណព្រះ គឺដូចជាការរាប់ការជាច្រើនសណ្ឋិកដែលព្រះបានធ្វើសម្រាប់យើង។

មានពេលមួយព្រះយេស៊ូវបានជួបមនុស្សកើតឃ្លង់១០នាក់ នៅជាយដែនក្រុងសាំម៉ារី តាមផ្លូវព្រះអង្គទៅទីក្រុងយេរូសាឡិម។ ព្រះអង្គក៏បានប្រោសពួកគេឲ្យជា តែមានតែម្នាក់ទេ ដែលបានត្រឡប់មកនិយាយអរព្រះគុណព្រះអង្គ។ ចុះ៩នាក់ទៀត តើនៅឯណា? ពួកគេប្រាកដជាអរសប្បាយ នឹងអំណាយនៃការប្រោសឲ្យជានោះខ្លាំងពេកហើយ បានជាភ្លេចព្រះយេស៊ូវ ដែលជាអ្នកប្រទាន។ ខ្ញុំចង់បន្ទោសពួកគេ តែក៏បានធ្វើដូចពួកគេជាច្រើនដងមកហើយដែរ។ អ្នកដែលត្រឡប់មកវិញនោះជាជនជាតិសាំម៉ារី។ គាត់បានក្រាបនៅទៀបព្រះបាតព្រះយេស៊ូវ ដោយអរព្រះ

គុណព្រះអង្គ សម្រាប់ការអ្វីដែលព្រះអង្គបានធ្វើ"។ ព្រះយេស៊ូវក៏បានប្រាប់គាត់ថា "ចូរក្រោកឡើងទៅចុះ សេចក្តីជំនឿអ្នកបានសង្គ្រោះអ្នកហើយ"(លូកា ៧:៥០)។

ព្រះយេស៊ូវមិនគ្រាន់តែបានប្រាប់គាត់ថា "ជំនឿរបស់អ្នកប្រោសឲ្យអ្នកជា" ប៉ុណ្ណោះទេ។ ព្រះអង្គថែមទាំងបានមានបន្ទូលថា "ជំនឿរបស់អ្នកបានសង្គ្រោះ អ្នកហើយ"។

ការដឹងគុណដ៏ពិត ធ្វើឲ្យយើងត្រឡប់មកអរព្រះគុណព្រះ។ យើងត្រូវធ្វើការសម្រេចចិត្តជ្រើសរើស។ យើងអាចចេញទៅតាមផ្លូវរបស់យើង ជាមួយនឹងការអ្វីដែលព្រះប្រទានយើង ឬយើងអាចត្រឡប់មកព្រះយេស៊ូវ ហើយថ្វាយបង្គំព្រះអង្គសម្រាប់ការអ្វីដែលព្រះអង្គបានធ្វើសម្រាប់យើង។

បើយើងផ្តោតទៅលើអំណោយយើង នោះយើងបានព្រះពរតែមួយរយៈពេល។ ចូរផ្តោតចិត្តទៅលើព្រះដែលជាអ្នកប្រទានអំណោយវិញ នោះយើងនឹងបានព្រះពរអស់កល្បជានិច្ច។

# លំនាំនៃការអធិស្ឋាន

*ព្រះអង្គជាព្រះដែលគ្រប់គ្រងលើទាំងអស់*

"ឱព្រះយេហូវ៉ា ជាព្រះនៃអ៊ីស្រាអែល ឰយុកោយើងរាល់គ្នាអើយ សូមឲ្យទ្រង់បានព្រះពរនៅអស់កល្បជានិច្ច។ ឱព្រះយេហូវ៉ាអើយ ភាពដ៏ធំ និងព្រះចេស្តា សិរីល្អ ជ័យជំនះ និងតេជានុភាព នោះសុទ្ធតែជារបស់ផងទ្រង់ ដ្បិតគ្រប់ទាំងអស់ដែលនៅលើមេឃ និងនៅផែនដី ជារបស់ផងទ្រង់ ឱព្រះយេហូវ៉ាអើយ រាជ្យនេះក៏ជារបស់ផងទ្រង់ដែរ ហើយទ្រង់បានដំកើងឡើង ជាប្រធានលើទាំងអស់។ ទ្រព្យសម្បត្តិ និងកេរ្តិ៍ឈ្មោះក៏មកអំពីទ្រង់ ហើយគឺទ្រង់ដែលគ្រប់គ្រងលើទាំងអស់ នៅព្រះហស្តទ្រង់មានទាំងព្រះចេស្តា និងឥទ្ធិឫទ្ធិ ហើយទ្រង់មានអំណាចនឹងលើកជាធំ ហើយប្រោសឲ្យមានកំឡាំងដល់មនុស្សទាំងអស់។ ដូច្នេះ ឱព្រះនៃយើងរាល់គ្នាអើយ យើងខ្ញុំអរព្រះគុណដល់ទ្រង់ ហើយក៏លើកសរសើរព្រះនាមទ្រង់ដ៏មានសិរីល្អ។ តែតើទូលបង្គំជាអ្វី ហើយរាស្ត្ររបស់ទូលបង្គំនេះជាអ្វី ដែលយើងខ្ញុំរាល់គ្នាអាចនឹងថ្វាយដង្វាយយ៉ាងនេះ ដោយស្ម័គ្រពីចិត្តបាន ដ្បិតគ្រប់របស់ទាំងអស់មកពីទ្រង់ យើងខ្ញុំរាល់គ្នាបានយកតែពីព្រះហស្តទ្រង់ ថ្វាយដល់ទ្រង់វិញ។ ពីព្រោះយើងខ្ញុំរាល់គ្នាជាអ្នកដទៃសុទ្ធនៅចំពោះទ្រង់ ហើយជាពួកអ្នកដែលគ្រាន់តែស្នាក់នៅប៉ុណ្ណោះ

ដូចជាពួកឰយុកោយើងខ្ញុំរាល់គ្នាដែរ វេលាអាយុយើងខ្ញុំរាល់គ្នានៅផែនដីនេះ នោះប្រៀបដូចជាស្រមោលទេ គ្មានអ្វីជាជាប់ស្ថិតស្ថេរបានឡើយ។-១របាក្សត្រ ២៩:១០-១៥



*"បើគ្មានព្រះ យើងគ្មានសង្ឃឹមអ្វីទេ។ បើគ្មានព្រះយេស៊ូវទេ នោះយើងប្រាកដជាបាត់បង់អស់កល្បជានិច្ច ដោយគ្មានក្តីសង្ឃឹម។"*

### *អរព្រះគុណព្រះអង្គដែលបានបង្កើតទូលបង្គំ*

ដ្បិតគឺទ្រង់ដែលបានបង្កើតចិត្តថ្លើមនៃទូលបង្គំ ហើយបានផ្សំគ្រឿងនៃទូលបង្គំនៅក្នុងផ្ទៃម្តាយ។ ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់ ដ្បិតទ្រង់បានបង្កើតទូលបង្គំមកយ៉ាងគួរកោត គួរអស្ចារ្យ ឯស្នាដៃនៃទ្រង់ ក៏សុទ្ធតែអស្ចារ្យទាំងអស់ ព្រលឹងទូលបង្គំក៏ដឹងច្បាស់ហើយ។ កាលទូលបង្គំកើតមាននៅទីកំបាំង ហើយបានសូន្យធ្វើបែបចំឡែកៗនៅទីទាបនៃផែនដី នោះគ្រោងកាយរបស់ទូលបង្គំមិនកំបាំងនឹងទ្រង់ទេ។ ព្រះនេត្រទ្រង់បានឃើញធាតុនៃទូលបង្គំ ក្នុងកាលដែលមិនទាន់មានរូបរាងនៅឡើយ ទាំងអស់បានកត់ទុកក្នុងបញ្ជីរបស់ទ្រង់ គឺអស់ទាំងថ្ងៃអាយុ ដែលបានតម្រូវឲ្យទូលបង្គំរស់នៅ ក្នុងកាលដែលមិនទាន់មានថ្ងៃណាមួយនោះនៅឡើយ។ ឱព្រះអង្គអើយ ព្រះដំរិះរបស់ទ្រង់មានដំឡៃវិសេស ដល់ទូលបង្គំណាស់ហ្ន៎ ក៏មានចំនួនច្រើនណាស់ផង។ បើសិនជាទូលបង្គំនឹងខំរាប់ចំនួន នោះមានច្រើនជាងគ្រាប់ខ្សាច់ទៅទៀត កាលណាទូលបង្គំភ្ញាក់ឡើង នោះទូលបង្គំនៅជាមួយនឹងទ្រង់នៅឡើយ។-ទំនុកដំកើង ២៨:៦-៧

### *អរព្រះគុណព្រះអង្គ សម្រាប់ព្រះរាជសារដ៏សាមញ្ញ អំពីសេចក្តីសង្គ្រោះ!*

ឱព្រះវរបិតា ជាព្រះអម្ចាស់នៃស្ថានសួគ៌ និងផែនដីអើយ ទូលបង្គំសរសើរដល់ទ្រង់ ដោយព្រោះទ្រង់លាក់សេចក្តីទាំងនេះនឹងពួកអ្នកប្រាជ្ញ ហើយនិងពួកឈ្លាសវៃ តែបានសំដែងឲ្យពួកកូនក្មេងយល់វិញ។ ហ្នឹងហើយ ព្រះវរបិតាអើយ ដ្បិតទ្រង់បានសព្វព្រះហឫទ័យយ៉ាងដូច្នោះ។-ម៉ាថាយ ១១:២៥-២៦

# លោកអ្នកអាចអធិស្ឋាន ដោយផ្ដើមដោយពាក្យ តាមលំនាំខាងក្រោម

*អរព្រះគុណព្រះអង្គដែលគង់នៅក្បែរទូលបង្គំ*

ឱព្រះអង្គអើយ យើងខ្ញុំអរព្រះគុណដល់ទ្រង់ យើងខ្ញុំអរព្រះគុណដោយព្រោះព្រះនាមទ្រង់ ស្ថិតនៅជិត មនុស្សទាំងឡាយប្រកាសប្រាប់ពីការអស្ចារ្យរបស់ទ្រង់។
-ទំនុកដំកើង ៧៥:១

*អរព្រះគុណព្រះអង្គ ដែលបានឆ្លើយតបការអធិស្ឋានរបស់ទូលបង្គំ*

ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់ ដ្បិតទ្រង់បានឆ្លើយមកទូលបង្គំ ហើយបានត្រឡប់ជាសេចក្ដីសង្គ្រោះដល់ទូលបង្គំ។-ទំនុកដំកើង ១១៨:២១

**លោកចន ដន(John Donne)** ដែលជាកវីកំណាព្យជនជាតិអង់គ្លេស នៅសតវត្សរ៍ទី១៦ បានរៀបរាប់អំពីការពិបាកនៃក្នុងការអធិស្ឋាន ហើយគ្រីស្ទបរិស័ទដែលព្យាយាមអធិស្ឋាន ឲ្យបានលើស៥នាទី អាចយល់អំពីបញ្ហានេះ។ គឺដូចដែលគាត់បានមានប្រសាសន៍ថា "ខ្ញុំបានក្រាបចុះ នៅក្នុងបន្ទប់ខ្ញុំ ខ្ញុំបានយាងព្រះវត្តមានព្រះអង្គ តែខ្ញុំបានបែកអារម្មណ៍ ដោយសារតែសម្លេងសត្វរុយហើរ នៅក្បែរត្រចៀកខ្ញុំ សម្លេងកៅអី និងទ្វារលាន់ងេតង៉ត ... តែខ្ញុំខំបន្តទូលថ្វាយព្រះអង្គ ដោយកាយវិការបែបអធិស្ឋាន គឺភ្នែកមើលទៅលើ ជង្គង់លុតចុះ គឺដូចជាអធិស្ឋានពិតៗ ហើយបើព្រះ ឬទេវតារបស់ព្រះអង្គសួរខ្ញុំថា តើខ្ញុំបានគិតអំពីព្រះអង្គ ត្រង់ចំណុចណា ក្នុងពេលអធិស្ឋានឬទេ? នោះខ្ញុំមិនអាចឆ្លើយបានទេ។ ជួនកាល ខ្ញុំភ្លេចថា ខ្លួនឯងត្រូវទូលប្រាប់ព្រះអង្គអំពីអ្វី។ ខ្ញុំចាំអំពីការសប្បាយកាលពីថ្ងៃម្សិលមិញ ហើយខ្លាចគ្រោះថ្នាក់នៅថ្ងៃស្អែក។ ចំបើងនៅក្រោមជង្គង់ខ្ញុំ សម្លេងនៅក្នុងត្រចៀកខ្ញុំ ពន្លឺចាំងភ្នែកខ្ញុំ ឬការអ្វីមួយ ដែលរំខានខ្ញុំ...ធ្វើឲ្យខ្ញុំពិបាកអធិស្ឋាន"។

លោកអូរីជិន(Origen) ស្ថិតក្នុងចំណោមអ្នកបង្កើតពួកជំនុំសម័យដើម។ គាត់បានសរសេរសេចក្តីអធិស្ឋានតាមលំនាំព្រះគម្ពីរ ដែលមានពេញទៅដោយ "ការប្រកាសដ៏អស្ចារ្យជាច្រើន"។ ការអធិស្ឋានតាមលំនាំព្រះបន្ទូលព្រះ ដែលមានចែងក្នុងព្រះគម្ពីរ ជួយឲ្យយើងអរសប្បាយក្នុងព្រះអង្គ ហើយរកឃើញក្តីសង្ឃឹម និងក្តីអំណរជាថ្មី។

ព្រះទ្រង់អាចប្រទានពរអ្នក ពេលអ្នកអធិស្ឋាន! សូមឲ្យព្រះអម្ចាស់នៃក្តីស្រឡាញ់ នាំអ្នកចូលកាន់តែជិត ហើយញញឹមមកកាន់អ្នក ពេលអ្នកអធិស្ឋាន តាមលំនាំព្រះបន្ទូល និងពាក្យសន្យារបស់ព្រះអង្គ។

# ក្រុមសៀវភៅការរុករកឃើញ

*ការងារបេសកកម្មរបស់យើងខ្ញុំ គឺដើម្បីឲ្យមនុស្សគ្រប់រូបមានឱកាសទទួល និងមានការយល់ដឹងអំពីប្រាជ្ញានៃព្រះគម្ពីរ ដែលធ្វើឲ្យជីវិតផ្លាស់ប្រែ ។*

ក្រុមសៀវភៅការរុករកឃើញ បកស្រាយអំពីសេចក្តីពិតនៃព្រះយេស៊ូវគ្រីស្ទ ដល់លោកិយ ដោយប្រើធនធានដែលមានគុណភាព ដែលគួរឲ្យចាប់អារម្មណ៍ និងអាចរកបាន ដែលបង្ហាញថា ព្រះគម្ពីរមានសារៈសំខាន់បំផុត ចំពោះគ្រប់ផ្នែកទាំងអស់នៃជីវិត។ កូនសៀវភៅ នៅក្នុងក្រុមសៀវភៅការរុករកឃើញ គឺអាចរកបាន ដោយឥតគិតថ្លៃ ហើយអាចត្រូវបានប្រើសម្រាប់ការសិក្សាផ្ទាល់ខ្លួន ក្នុងក្រុមតូច ឬក្នុងការងារឈោងចាប់។

យើងខ្ញុំសូមអរគុណ សម្រាប់ការគាំទ្រ ធនធានរបស់ក្រុមសៀវភៅការរុករកឃើញ និងអង្គការនំម៉ាណាប្រចាំថ្ងៃ។ មានមនុស្សជាច្រើនបានដាក់ដង្វាយឧបត្ថម្ភ ទោះតិចតួច ឬច្រើនក្តី ដល់អង្គការនំម៉ាណាប្រចាំថ្ងៃ ដើម្បីឲ្យឈោងចាប់អ្នកដទៃ ដោយប្រាជ្ញានៃព្រះគម្ពីរដែលធ្វើឲ្យជីវិតផ្លាស់ប្រែ។ យើងខ្ញុំមិនបានទទួលមូលនិធី ឬប្រាក់ឧបត្ថម្ភពីក្រុម ឬនិកាយណាមួយឡើយ។